# បង្ក្រាបអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ

## ការឃុំខ្លួនតាមអំពើចិត្តនិងការរំលោភផ្សេងទៀត ប្រឆាំងនឹងអ្នកប្រកបមុខរបររកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជា

### I. សេចក្តីសង្ខេប

បន្ទាប់ពីការសួរចម្លើយយើងខ្ញុំ ប៉ូលីសបានរុញខ្ញុំចូលទៅក្នុងបន្ទប់ ដែលមានគ្រែបត់មួយនៅទីនោះ - វាជាកន្លែងឃុំខ្លួនជនសង្ស័យពីបទព្រហ្មទណ្ឌ។ នៅយប់ដំបូង ប៉ូលីសប្រាំនាក់បានរំលោភខ្ញុំ និងនៅយប់ទីពីរ ប៉ូលីសប្រាំមួយនាក់រំលោភខ្ញុំ។ ពួកគេបានវាយខ្ញុំ ព្រោះខ្ញុំប្រកែក។

-ស្រ្តីប្រកបមុខរបររកស៊ីផ្លូវភេទបានពិពណ៌នាពីការប្រព្រឹត្តមកលើខ្លួននាង បន្ទាប់ពីការចាប់ខ្លួនជាមួយនឹងស្រ្តីប្រកបរបររកស៊ីផ្លូវភេទដទៃទៀត នៅក្បែរវិមានឯករាជ្យ ក្នុងរាជធានីភ្នំពេញ។

ប៉ូលីសបីនាក់បានវាយដំច្រំធាក់ខ្ញុំខ្លាំងណាស់...ប៉ូលីសម្នាក់ក្នុងចំណោមពួកគេទាំងបីនាក់ បានយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ រួចកេះកៃ ប៉ុន្តែអត់ផ្ទុះគ្រាប់ទេ។ ពួកគេទាត់កញ្ជឹងករបស់ខ្ញុំ ចង្កេះរបស់ខ្ញុំនិងវាយក្បាលរបស់ខ្ញុំនិងខ្លួនខ្ញុំជាមួយដងអំបោស។ វាយប្រហែលកន្លះម៉ោង។

-ស្រីស្រស់ (Transgender woman) ប្រកបរបររកស៊ីផ្លូវភេទ ឃុំខ្លួននៅឯ ប៉ុស្តិប៉ូលីសមួយ នៅរាជធានីភ្នំពេញ។

ពីរថ្ងៃក្រោយពីខ្ញុំបានមកដល់ ខ្ញុំបានព្យាយាមរត់គេចខ្លួន តែគេចាប់ខ្ញុំបាន។ ពួកអ្នកយាមប្រាំនាក់បានវាយដំខ្ញុំ។ ពេលខ្ញុំយកដៃទៅរងមុខនិងក្បាលពីការវាយដំ ពួកគេវាយដៃរបស់ខ្ញុំ។ អ្នកយាមម្នាក់គំរាមអារកខ្ញុំ ប្រសិនបើខ្ញុំព្យាយាមរត់គេចជាលើកទីពីរ និងនិយាយថានឹងដុតសពខ្ញុំចោលនៅទីនោះ។

-ស្រ្តី ប្រកបរបររកស៊ីផ្លូវភេទជាប់ឃុំឃាំងនៅមណ្ឌលសង្គមកិច្ចព្រៃស្ពឺក្បែរ រាជធានីភ្នំពេញ។

នៅក្នុងប្រទេសកម្ពុជា ជនដែលមានមុខងារការពារច្បាប់ ជាញឹកញាយគឺជាជនដែលប្រព្រឹត្តអំពើរំលោភបំពានដ៏អាក្រក់បំផុត។ ជាពិសេស ស្រ្តីប្រកបរបររកស៊ីផ្លូវភេទ ដឹងការពិតទាក់ទងនឹងរឿងនេះ។ ស្រ្តីនិងកុមារដែលពាក់ព័ន្ធក្នុងមុខរបររកស៊ីផ្លូវភេទ ប្រឈមមុខនឹង ការវាយដំ ការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ ការជំរិតយកលុយ ការចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្ត ការធ្វើការងារដោយបង្ខំ និងការប្រព្រឹត្តបែបបន្ទាបបន្ថោក និង ឃោរឃៅដទៃទៀត ក្នុងកណ្តាប់ដៃរបស់ប៉ូលីស របស់អ្នកយាមតាមសួនច្បារសាធារណៈ មន្ត្រីរដ្ឋាភិបាល និងជនទាំងឡាយដែលធ្វើការនៅក្នុងមជ្ឈមណ្ឌលនិងការិយាល័យ ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (MOSAVY)។

អ្នកប្រកបរបររកស៊ីផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា មន្ត្រីប៉ូលីស បានវាយ លើពួកគេដោយប្រើកណ្តាប់ដៃ ព្រនង់ ដំបងឈើ និងប្រើដំបងឆក់។ មន្ត្រីប៉ូលីស បានគំរាមកំហែង អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ដោយអាវុធផងដែរ។ ក្នុងឱកាសខ្លះ មន្ត្រីប៉ូលីសបានរំលោភស្រ្តីប្រកបមុខរបររកស៊ីផ្លូវភេទ ក្នុងអំឡុងពេលដែលពួកគេស្ថិតក្នុង

ការឃុំឃាំងរបស់ប៉ូលីស។ អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ខ្លះបានពិពណ៌នាអំពីការឃុំឃាំង នៅក្នុងមជ្ឈមណ្ឌលសង្គមកិច្ចថា ពួកគេស្ថិតក្នុងស្ថានភាពគួរឲ្យរន្ធត់ ជាមួយនឹងការដាក់កំហិតដល់សេរីភាពក្នុងការធ្វើដំណើរ ទទួលរងឬបានឃើញការវាយដំ ឬការរំលោភ សេពសន្ថវៈ និងមានអាហារ និងការថែទាំផ្នែកពេទ្យមិនគ្រប់គ្រាន់។

អំពើហិង្សានិងការរំលោភភាគច្រើនផ្សេងទៀត ដែលប្រព្រឹត្តដោយប៉ូលីស នៅរាជធានីភ្នំពេញ ហាក់ដូចជាអាក្រក់ជាងនៅក្នុងខែត្របាត់ដំបង បន្ទាយមានជ័យ និងសៀមរាប និងបណ្តាខែត្រដទៃទៀត ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានធ្វើការស្រាវជ្រាវ។ មន្ត្រីប៉ូលីសនៅតាមស្ថានីយ៍ប៉ូលីសនានា ក្នុងខណ្ឌដូនពេញ និងខណ្ឌចំការមនក្នុងរាជធានីភ្នំពេញ លេចធ្លោខាងការប្រព្រឹត្តអំពើរំលោភ ។ ស្ថានីយ៍ប៉ូលីសទាំងនេះ មានការទាក់ទងច្រើនបំផុត ជាមួយអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ពីព្រោះស្ថានីយ៍ទាំងនេះ ស្ថិតនៅក្បែរសួន សាធារណៈ ជាទីកន្លែងដែលមានអ្នកប្រកបមុខរបររកស៊ីផ្លូវភេទភាគច្រើនទៅទីនោះ ជា ញឹកញាប់។

ប៉ូលីសជំរិតយកលុយ និងប៉ូលីសទាររអោយបង់ប្រាក់សំណូក មានភាពល្បីរន្ទឺនៅគ្រប់ខែត្រ ទាំងអស់ ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានធ្វើការសិក្សាស្រាវជ្រាវ។ ពេលខ្លះប៉ូលីស បានបង្ខំឲ្យអ្នកប្រកបរបររកស៊ីផ្លូវភេទ បង់ប្រាក់លោះ មួយចំនួន ឬ ក្នុងករណីដ៏អាក្រក់ បំផុតនោះគឺ បានបង្ខំស្ត្រីឲ្យរួមភេទជាមួយពួកគេជាថ្នូរនឹងការដោះលែង។ ស្ត្រីប្រកបរបរ រកស៊ីផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ប៉ូលីសបានយកលុយរបស់ ពួកគេនិងវត្ថុមានតម្លៃ។ អ្នកប្រកបរបររកស៊ីផ្លូវភេទដែលយើងបានជួបនិយាយជាមួយ គ្រប់រូប ដែលរួមមានទាំងកុមារក្នុងមុខរបរនេះផង សុទ្ធតែបានបង់ប្រាក់សំណូក ឲ្យប៉ូលីសនៅក្នុងដំណាក់កាលណាមួយ។

នៅក្នុងរាជធានីភ្នំពេញ ប៉ូលីសមិនមែនជាកងកម្លាំងសន្តិសុខតែម្នាក់ឯង ដែលរំលោភស្ត្រី ប្រកបរបររកស៊ីផ្លូវភេទប៉ុណ្ណោះទេ។ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទបានរាយការណ៍មកអង្គការ ឃ្លាំមើលសិទ្ធិមនុស្សផងដែរអំពីឧប្បត្តិហេតុហិង្សា ពាក់ព័ន្ធនឹងកងសន្តិសុខសួនច្បារ សាធារណៈរបស់សាលារាជធានីភ្នំពេញ ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ នីកា បានពណ៌នាអំពីការវាយដំប្រព្រឹត្តឡើងថ្មីៗដោយឆ្មាំសន្តិសុខ - ដែលជានិយោជិករបស់សាលា រាជធានីភ្នំពេញ - នៅឯសួនច្បារក្បែរផ្សារចាស់ រាជធានីភ្នំពេញ។ នាងបាននិយាយថា ៖

ដំបូង សន្តិសុខម្នាក់បានមក ហើយទាត់ខ្ញុំ ... បន្ទាប់មកសន្តិសុខបីនាក់បានមកដល់។ សន្តិសុខពីរនាក់ចាប់ដៃទាំងពីររបស់ខ្ញុំជាប់ ដោយទុកឲ្យពីរនាក់ទៀតវាយខ្ញុំ។ ពួកគេទះមុខខ្ញុំ។ ពួកគេដូចជាស្រវឹងស្រាបន្តិច។ ពួកគេវៃក្បាលខ្ញុំនឹងដំបងឫស្សី និងវិទ្យុរបស់ពួកគេ និងវាយសព្វកន្លែងទាំងអស់។ ពួកគេចាប់ហែកអាវខ្ញុំ។ ប៉ូលីសបានមកកាត់តាមនោះ តែគេអត់រវល់នឹងខ្ញុំទេ សន្តិសុខបន្តវាយខ្ញុំជិតកន្លះម៉ោង។ មនុស្សជាច្រើននាក់ឃើញខ្ញុំ តែគេរាល់គ្នាខ្លាច មិនហ៊ានជួយខ្ញុំទេ។ ប្រធានសន្តិសុខប្រាប់កូនចៅផ្សេងទៀតថាបើឃើញខ្ញុំទៅទីនោះម្តងទៀត ត្រូវវាយខ្ញុំឲ្យងាប់។

ឧប្បត្តិហេតុហិង្សា ការចាប់ខ្លួននិងឃុំខ្លួនខុសច្បាប់ខ្លះ ដែលបានប្រព្រឹត្តទៅលើ អ្នកប្រកប របររកស៊ីផ្លូវភេទ គឺមានលក្ខណៈបែបឱកាសនិយម។ ការធ្វើការងារនៅតាមដងផ្លូវ និងនៅលើសួនច្បារ នាំឲ្យអ្នកប្រកបមុខរបររកស៊ីផ្លូវភេទងាយទទួលរងគ្រោះពីប៉ូលីស និង សន្តិសុខការពារសួនច្បារ ដែល ពួកគេ ដឹងខ្លួនថា នឹងមិនមាននរណាមកចាប់ពួកគេឲ្យទទួលខុសត្រូវចំពោះអំពើរំលោភដែលពួកគេបានប្រព្រឹត្តនោះឡើយ។ ការរំលោភដទៃទៀត កើតឡើងក្នុងពេលមានការចាត់វិធានការ បង្រ្កាបនិង ចុះចាប់ប្រមូលជាទៀងទាត់ដោយប៉ូលីស និងអាជ្ញាធរខ័ណ្ឌ ជាពិសេសនៅពេលសំដៅចាប់តែអ្នកប្រកបរបររកស៊ីផ្លូវភេទ និងនៅពេលផ្សេងទៀតសំដៅចាប់ អ្នកប្រកបរបររកស៊ីផ្លូវភេទ ក្នុងចំណោមក្រុមដទៃទៀតនៃប្រជាពលរដ្ឋដែលគេចាត់ជាកាកសំណល់សង្គម ដែលគេឃើញនៅតាមដងផ្លូវ។

អ្នកប្រកបរបររកស៊ីផ្លូវភេទ ប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ច្រើនដោយសារការងារប្រចាំថ្ងៃ របស់ពួកគេដូចជាអំពើហិង្សា ការរំលោភសេពសន្ថវៈ ការប្លន់ ការបៀតបៀនកេរ្តិ៍ខ្មាស់ និងការរំលោភដទៃទៀតដែលប្រព្រឹត្តដោយអតិថិជន បុគ្គលដទៃទៀត និងអ្នករដ្ឋការ។ របាយការណ៍នេះ ពិនិត្យត្រឹមតែស្ថានភាពជាក់លាក់អំពីការរំលោភដោយប៉ូលីស សន្តិសុខ សួនច្បានៅរាជធានីភ្នំពេញ និងនិយោជិតនៅឯមជ្ឈមណ្ឌលសង្គមកិច្ចដែលគ្រប់គ្រងដោយ រដ្ឋាភិបាល។

ជាទូទៅ អាជ្ញាធរមិនធ្វើការបែងចែករវាងនីតិជនដែលរងការជួញដូរ និង នីតិជនក្នុងការងារ ប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត ទេ។ ពួកគេបញ្ជូនអ្នកប្រកបរបររកស៊ីផ្លូវភេទ រួមទាំងជនរងគ្រោះដោយការជួញដូរ និងកុមារ ទៅមន្ទីរសង្គមកិច្ចរាជធានី ដែលក្រោយមក បញ្ជូនពួកគេទៅកាន់មណ្ឌលអង្គការក្រៅរដ្ឋាភិបាល ឬមណ្ឌលសង្គមកិច្ចរដ្ឋាភិបាល (ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។ មានត្រឹមតែប៉ូលីសជំនាញប្រឆាំងការជួញដូរប៉ុណ្ណោះ បែកចែកជនរងគ្រោះនៃការជួញដូរនិងកុមារពីអ្នកប្រកបរបររកស៊ីផ្លូវភេទស្ម័គ្រចិត្ត និងបញ្ជូនស្រ្តីនិងកុមារដែលគេជួញដូរទៅមណ្ឌលប្រឆាំងការជួញដូរជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ យោងតាមស្រ្តី អ្នកប្រកបរបររកស៊ីផ្លូវភេទ សមាជិកមួយចំនួនរបស់ប៉ូលីសជំនាញប្រឆាំងការជួញដូរក្នុងរាជធានីភ្នំពេញ បានជាប់ពាក់ព័ន្ធក្នុងការព្យាយាមជំរិតទារលុយពីស្រ្តីប្រកបមុខរបររកស៊ីផ្លូវភេទ ។ ការបោសសម្អាតតាមដងផ្លូវភាគច្រើន ដឹកនាំដោយប៉ូលីសសណ្តាប់ធ្នាប់ ថ្នាក់សង្កាត់ ខ័ណ្ឌ ឬរាជធានី។

ការរំលោភបំពាននៅឯមជ្ឈមណ្ឌលសង្គមកិច្ច

ប៉ូលីស ឬមន្រ្តីសង្គមកិច្ចរាជធានី ជាញឹកញយបញ្ជូន អ្នកប្រកបរបររកស៊ីផ្លូវភេទ និង អ្នកដទៃទៀតដែលគេបានចាប់ខ្លួនក្នុងយុទ្ធនាការបង្ក្រាប ទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល ឬទៅកាន់មណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុង ឆ្នាំ២០០៨ ក្រុមសិទ្ធិមនុស្ស និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានចងក្រងជាឯកសារនូវការរំលោភ និងស្ថានភាពទាំងឡាយ ក្នុងមជ្ឈមណ្ឌលសង្គមកិច្ចពីរកន្លែងរបស់រដ្ឋាភិបាល គឺកោះគរ (ឬកោះរំដួល) និងព្រៃស្ពឺ រួមទាំងមរណភាព ការរំលោភសេពសន្ថវៈ ទារុណកម្ម ការវាយដំ និងការដាក់កំហិតខុសច្បាប់ លើសេរីភាពធ្វើដំណើរ។

មជ្ឈមណ្ឌលទាំងនោះ ជាគុកនរក។ ក្នុងខែមិថុនា ឆ្នាំ២០០៨ រដ្ឋាភិបាលបានដោះលែងអ្នកជាប់ឃុំឃាំងទាំងអស់ពីមណ្ឌលកោះគរ ដែលមានទីតាំងលើកោះមួយ ដែលធ្លាប់ជាទីកន្លែង ឃុំឃាំងរបស់ខ្មែរក្រហម។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលនោះមិនសកម្មទៀតទេ និងឈប់ទទួល មនុស្សទៅដាក់ឃុំទៀតហើយ ទោះជានៅមានបុគ្គលិកមណ្ឌលមួយនាក់ ឬក៏ពីរនាក់រស់នៅ ទីនោះក៏ដោយ។

អ្នកប្រកបរបររកស៊ីផ្លូវភេទ អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមាររស់តាមចិញ្ចើម ថ្នល់ និងអ្នកគ្មានទីលំនៅ ដែលគេឃុំទុកនៅព្រៃស្ពឺ បានរាយការណ៍ពីរបៀបដែលសមាជិកបុគ្គលិកនៅឯព្រៃស្ពឺ បានវាយទាត់ធាក់ ចាប់រំលោភសេពសន្ថវៈ និងធ្វើបាបអ្នកជាប់ឃុំ រួម ទាំងកុមារ។ ស្រ្តីប្រកបរបររកស៊ីផ្លូវភេទ ដែលគេឃុំនៅព្រៃស្ពឺ នៅខែមិថុនា នាពេលថ្មីៗនេះ ត្រូវបានគេទុកឲ្យនៅតែក្នុងបន្ទប់ និងអនុញ្ញាតឲ្យចាកចេញពីបន្ទប់ទៅងូតទឹក បាន ត្រឹមតែពីរដងប៉ុណ្ណោះក្នុងមួយថ្ងៃ ក្នុងទឹកស្រះកខ្វក់ ឬត្រូវដើរអមតាមដោយឆ្មាំការពារទៅកាន់បង្គន់។ មជ្ឈមណ្ឌលនេះមិនមានសម្ភារៈគ្រប់គ្រាន់ បុគ្គលិកគ្មានការហ្វឹកហ្វឺន និងគ្មានកម្មវិធីស្តារនីតិសម្បទាទេ។

បុប្ផា ត្រូវបានគេចាប់ខ្លួនច្រើនលើកច្រើនសារមកហើយ។ នាងបានពិពណ៌នាឲ្យអង្គការ ឃ្លាំមើលសិទ្ធិមនុស្សដឹងអំពីឧប្បត្តិហេតុមួយក្នុងឆ្នាំ២០០៨ ពេលដែលប៉ូលីសខ័ណ្ឌចាប់ខ្លួននាង។ ពេលនាងមិនព្រមផ្តល់លុយទៅឲ្យពួកគេ ពួកគេបានចាប់បោះនាងឡើងលើរថយន្ត ដែលជាកម្មសិទ្ធិរបស់ មន្ទីរសង្គមកិច្ចរាជធានី ហើយបានបញ្ជូននាងទៅព្រៃស្ពឺ។ នាងបាន និយាយថា ៖

ប្រាំបួនថ្ងៃដែលខ្ញុំស្ថិតនៅក្នុងមណ្ឌលព្រៃស្ពឺ គឺវាអាក្រក់ជាងការរស់នៅក្នុងឋាននរកទៅទៀត។ នៅថ្ងៃមកដល់ អ្នកយាមបានវាយខ្ញុំពីរដង យកដំបងឈើវាយលើត្រគាករបស់ ខ្ញុំ... អាហារគគ្រិចមែនទែន... គេយកទឹកពីស្រះអោយផឹក... នៅក្នុងបន្ទប់គេដាក់ធុង សំរាប់ ប្រើជាបង្គន់... យប់មួយនោះ អ្នកយាមបានមករករួមភេទជាមួយស្ត្រីស្រស់ស្អាតពីរនាក់ដែលដេកជាប់នឹងខ្ញុំនៅក្នុងបន្ទប់។ ស្ត្រីទាំងនេះត្រូវបានគេដោះលែងនៅថ្ងៃបន្ទាប់ ។ ខ្ញុំមានផ្ទុកមេរោគអេដស៍ ហើយខ្ញុំខកខានមិនបានលេបថ្នាំប្រឆាំងមេរោគអេដស៍ប៉ុន្មានថ្ងៃនោះ។

ជាលទ្ធផលនៃការស្វែងរកការគាំទ្ររបស់ អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ និងក្រុមសិទ្ធិ មនុស្ស អំពីស្ថានភាពរំលោភក្នុងមជ្ឈមណ្ឌលព្រៃស្ពឺ ក្នុងខែកក្កដាឆ្នាំ២០០៩ មន្ទីរសង្គមកិច្ចរាជធានី បានប្រកាសថាខ្លួនឈប់បញ្ជូនស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ទៅកាន់ទីនោះ ហើយ។ ជាជំនួសវិញ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដែលចាប់ដោយប៉ូលីសត្រូវតែបញ្ជូន ទៅអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាគាំទ្រ។

ទោះជាយ៉ាងណាក៏ដោយ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានដឹងថា យ៉ាងហោចណាស់ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ចំនួន ២០ នាក់ ត្រូវបានឃុំឃាំងនៅឯព្រៃស្ពឺ តាំងពីខែកក្កដាឆ្នាំ២០០៩មក។ ទោះបីជាចំនួននេះ បង្ហាញពីការថយចុះចំនួនស្ត្រី ប្រកបរបររកស៊ី ផ្លូវភេទ  ដែលគេឃុំឃាំងនៅទីនោះតាំងពីឆ្នាំ២០០៨ក៏ដោយ ដោយមានការលំបាកចូលទៅកាន់មណ្ឌលនេះ ចំនួននេះត្រូវបានគេពិចារណាថាជាចំនួនសារុបជាអប្បបរមាប៉ុណ្ណោះ។ ខណៈដែល ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ត្រូវបានគេបញ្ជូនទៅតាមមណ្ឌលអង្គការក្រៅរដ្ឋាភិបាល ដោយសារតែមានសំពាធពីក្រុមអ្នកគាំទ្រអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ប៉ុន្តែ ក្រុមដទៃទៀតរួមទាំងអ្នកគ្មានផ្ទះសំបែង ត្រូវបានគេបន្តបញ្ជូនទៅកាន់ព្រៃស្ពឺ។  ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដែលគេឃុំឃាំងនៅឯព្រៃស្ពឺ ក្នុងខែមិថុនាឆ្នាំ២០១០ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា បុគ្គលិកមណ្ឌលសង្គមកិច្ចបានប្រមានពួកគេថាពួកគេនឹងប្រឈមនឹងការឃុំឃាំងរហូតដល់ទៅបីខែក្នុងមណ្ឌលព្រៃស្ពឺ ប្រសិនបើពួកគេត្រូវបានគេចាប់ខ្លួននិងបញ្ជូនមកមន្ទីរសង្គមកិច្ចជាលើកទីពីរ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានកង្វល់ណាស់ដែលមណ្ឌលព្រៃស្ពឺនៅតែបើក។    ប្រសិនបើមិនមានការប្តេជ្ញាខាងនយោបាយពីរដ្ឋាភិបាលកម្ពុជាដើម្បីដោះស្រាយការរំលោភធ្ងន់ធ្ងរ ប្រឆាំងនឹងអ្នកគ្រប់គ្រងមណ្ឌលទាំងនេះទេ អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានជំនឿថាមណ្ឌលទាំងពីរនោះដែលនៅឯកោះគរនិងព្រៃស្ពឺគួរតែបិទជាអចិន្ត្រៃ។

មណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលព្រមទទួលយក ស្ត្រីប្រកប របររកស៊ីផ្លូវភេទ តាមការបញ្ជូនពីមន្ទីរសង្គមកិច្ច មានបទដ្ឋាន និងនីតិវិធីប្រតិបត្តិការផ្សេងៗគ្នា ប៉ុន្តែ មានស្ថានភាព ប្រសើរច្រើនជាងស្ថានភាពនៅក្នុងមជ្ឈមណ្ឌលសង្គមកិច្ច របស់រដ្ឋាភិបាល។ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនមិនឃុំឃាំងនីតិជនទេ ប៉ុន្តែផ្តល់សេវាកម្មនិងជម្រើសលើមូលដ្ឋានព្រមព្រៀង។

ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០០៩ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ បានប្រាប់ អង្គការ ឃ្លាំមើលសិទ្ធិមនុស្សថា មណ្ឌលអង្គការក្រៅរដ្ឋាភិបាលចំនួនពីរ បានឃុំឃាំងពួកគេតាមអំពើចិត្តអស់ពេលបីបួនថ្ងៃរហូតដល់បីបួនសប្តាហ៍។ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ពីរនាក់ដែលមានផ្ទុកមេរោគអេដស៍ បានរាយការណ៍ផងដែរថា មណ្ឌលអង្គការក្រៅរដ្ឋាភិបាល មួយបានបដិសេធការស្នើសុំឱសថប្រឆាំងមេរោគអេដស៍របស់ពួកគេ។ អង្គការក្រៅរដ្ឋា ភិបាល ដែលជាប់ចោទ បានច្រានចោលថា មិនមានជនណាម្នាក់ត្រូវបានឃុំឃាំងខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេទេ និងដោយបានប្រកែកលើកហេតុផលផងដែរថា ពួកគេ ត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីផ្តល់ការប្រឹក្សាយោបល់ដល់ស្ត្រីនិងកុមារី ដើម្បីឲ្យពួកគេជឿ និងស្នាក់នៅរៀនជំនាញ។ តាមពិត អង្គការក្រៅរដ្ឋាភិបាលមិនមានសិទ្ធិខាងផ្លូវច្បាប់ ដើម្បីរក្សាទុក ជនណាម្នាក់ប្រឆាំងឆន្ទៈរបស់ពួកគេឡើយ ហើយទោះជាការរក្សាទុក

អ្នកណាម្នាក់រយៈពេលមួយម៉ោងពីរ ឬមួយថ្ងៃពីរក៏ដោយ គឺចាត់ជាការដកហូតសេរីភាពខុសច្បាប់។ តាំងពីនោះមក អង្គការក្រៅរដ្ឋាភិបាលដែលជាប់ចោទទាំងនោះ បានជូនដំណឹងដល់អង្គការ ឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេបានផ្លាស់ប្តូរគោលនយោបាយរបស់ ពួកគេហើយ និងលែងឃុំឃាំងបុគ្គលណាម្នាក់ទៀតហើយ ទោះក្នុងរយៈពេលដ៏ខ្លីក៏ដោយ។ មិនមានករណីថ្មីនៃ ការឃុំឃាំងដោយអង្គការក្រៅរដ្ឋាភិបាល ត្រូវបានរាយការណ៍មក អង្គការឃ្លាំមើលសិទ្ធិមនុស្សទេនៅក្នុងឆ្នាំ២០១០នេះ។

ការបោសសម្អាតនិងវិធានការចុះបង្ក្រាបទៀងទាត់តាមកាលកំណត់

កំឡុងពេលវិធានការបង្ក្រាបប្រឆាំងនឹង អ្នកប្រកបរបររកស៊ីផ្លូវភេទ ដែលធ្វើឡើងដោយ ប៉ូលីសនិងអាជ្ញាធរដទៃទៀត បានប្រមូលផ្តុំយ៉ាងសំខាន់នូវចំណាប់អារម្មណ៍ពីសារព័តមានក្នុងឆ្នាំ២០០៨និង២០០៩ ដែលការបង្ក្រាបបែបនេះបានបន្តធ្វើជាច្រើនឆ្នាំមកហើយ។ មាន ភស្តុតាងជាច្រើនត្រូវបានបង្ហាញចំពោះការបង្ក្រាបតាមកាលកំណត់ទាំងនេះ។

ហេតុផលមួយដែលបានផ្តល់ឲ្យដោយអាជ្ញាធរមូលដ្ឋានគឺដើម្បី “រៀបចំដងផ្លូវ” និងថែរក្សាសណ្តាប់ធ្នាប់សង្គម។ អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ និងអ្នកគ្មានផ្ទះសំបែង កុមាររស់តាម ចិញ្ចើមថ្នល់ អ្នកសុំទាន និងអ្នកប្រើប្រាស់គ្រឿងញៀននៅតាមដងផ្លូវនៃរាជធានីភ្នំពេញ ត្រូវបានឡោមព័ទ្ធចាប់និងឃុំខ្លួនក្នុងប្រតិបត្តិការ ដែលអនុញ្ញាតពីអភិបាល និងអភិបាលរង រាជធានីភ្នំពេញ។

អាជ្ញាធររាជធានី បានធ្វើសេចក្តីថ្លែងជាសាធារណៈផងដែរថា អាជ្ញាធរត្រូវចាប់ អ្នករកស៊ីផ្លូវ ភេទ និងឃុំឃាំងពួកគេ ដើម្បីបង្ការការរីករាលដាលនៃជំងឺអេដស៍។ ឧទាហរណ៍ ពីរបីថ្ងៃមុនពិធីបុណ្យ “អុំទូក” ប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា គឺនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ លោក សុខ ពេញវុធ អភិបាលរងខ័ណ្ឌដូនពេញ បានផ្តល់ហេតុផលចំពោះការចាប់ខ្លួនស្ត្រី រកស៊ីផ្លូវភេទចំនួន១៧នាក់បញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានី ដោយនិយាយថា “យើងមិន ចង់ឃើញអ្នកប្រណាំងទូកនាំយកមេរោគអេដស៍/ជំងឺអេដស៍ទៅចំលងឲ្យប្រពន្ធរបស់ ពួកគេទេ។ យើងចង់ការពារបុរសទាំងនោះ ពីការឆ្លងមេរោគ ពេលពួកគេចូលរួមក្នុង ពិធីនេះហើយភ្លេចគិតពីសុខភាពនិងសុវត្ថិភាព។ “ ការបោសសម្អាតដងផ្លូវ និងការបង្ក្រាប តាមទីកន្លែងសេវាកម្សាន្តនានា មានការកើនឡើង ក្នុងអំឡុងនៃព្រឹត្តិការណ៍តំបន់ឬអន្តរជាតិធំៗដែលរៀបចំឡើងក្នុងរាជធានីភ្នំពេញ និងអំឡុងពិធីសាធារណៈសំខាន់ៗ ដូចជាថ្ងៃបុណ្យចូលឆ្នាំខ្មែរ (ពាក់កណ្តាលខែមេសា) និងថ្ងៃបុណ្យអុំទូក (ចុងខែតុលា ដើមខែវិច្ឆិកា)។

ហេតុផលមួយទៀតនោះ គឺការចាប់អារម្មណ៍តាមនឹកឃើញរបស់អាជ្ញាធរ ក្នុងការប្រយុទ្ធប្រឆាំងពេស្យាកម្ម និងជាបន្ទាប់នោះគឺការទាក់ទាញការចាប់អារម្មណ៍ពីម្ចាស់ជំនួយ និងការយកបញ្ហាជួញដូរ ដាក់បញ្ចូលគ្នាជាមួយ មុខរបររកស៊ីផ្លូវភេទ។

ការបញ្ចូលបញ្ហាជួញដូរជាមួយបញ្ហាមុខរបររកស៊ីផ្លូវភេទ

អំពើជួញដូរស្ត្រីនិងកុមារសំរាប់បេស្យាចារ គឺជាបញ្ហាមួយនៅក្នុងប្រទេសកម្ពុជា ដែលដុតបញ្ឆេះដោយអំពើពុករលួយ និងការខ្វះខាតនូវឆន្ទៈនយោបាយក្នុងការនាំខ្លួនជនជួញដូរមនុស្សមកកាត់ទោស។ ថ្វីបើមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការយល់ដឹង និងការពារជនរងគ្រោះនៃការជួញដូរក៏ដោយ ក៏ស្ត្រីនិងកុមារ នៅតែបន្តទទួលរងនូវការជួញដូរក្នុងប្រទេសកម្ពុជាដដែល។

កិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស មានផលវិបាកទាំងពីរយ៉ាងគឺជាវិជ្ជមាននិងជាអវិជ្ជមាន។ គំនិតផ្តួចផ្តើមមួយចំនួនរបស់រដ្ឋាភិបាល បានផ្តោតលើបញ្ហាការជួញដូរ និងបញ្ហាមុខរបររកស៊ីផ្លូវភេទរួមបញ្ចូលគ្នាតែម្តង និងបានស្វះស្វែងលប់បំបាត់មុខរបររកស៊ីផ្លូវភេទ ជាមធ្យោបាយមួយក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ ក្នុងឆ្នាំ២០០៧ ក្រសួងមហាផ្ទៃ

បានដឹកនាំយុទ្ធនាការប្រឆាំងនឹងការជួញដូរ និងមុខរបររកស៊ីផ្លូវភេទ ដែលយុទ្ធនាការនោះ បានតំរូវអោយប៉ូលីស បង្ក្រាបទីកន្លែងកម្សាន្ត ជាទីកន្លែងដែលស្រ្តីនិងកុមារលក់ភេទ។ ប៉ូលីសនិងមន្ត្រីដទៃទៀតក្នុងរាជធានីភ្នំពេញ បានដឹកនាំទ្រង់ទ្រាយធំនូវការបង្ក្រាប និង បោសសម្អាត ស្ត្រីប្រកបមុខរបររកស៊ីផ្លូវភេទចេញពីដងផ្លូវនិងសួនច្បារនៃរាជធានីភ្នំពេញ។ ប៉ូលីសបានបិទផ្ទះបនជាច្រើនកន្លែងក្នុងប្រទេសផងដែរ។

ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ ដោយមានការជំរុញពីម្ចាស់ជំនួយបរទេស ជាពិសេសសហរដ្ឋអាមេរិក។ រដ្ឋបាលសហរដ្ឋអាមេរិករបស់រដ្ឋកាលលោកប៊ូស កាលនោះ បានជំរុញប្រទេស កម្ពុជាឲ្យអនុម័តច្បាប់ប្រឆាំងការជួញដូរដ៏ទូលំទូលាយមួយ តាមរយៈការវាយតម្លៃប្រចាំឆ្នាំ ស្តីពីការជួញដូរនៅក្នុងប្រទេសកម្ពុជារបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។

ច្បាប់ប្រឆាំងការជួញដូរ មានចំណុចវិជ្ជមានខ្លះក្នុងការស្វះស្វែងដាក់ជាបទឧក្រិដ្ឋលើសកម្មភាពជាក់លាក់ស្របតាមបទដ្ឋានអន្តរជាតិ រួមទាំងការងាររកស៊ីផ្លូវភេទដោយបង្ខំ និងទម្រង់ការងារបង្ខំដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយ ទិដ្ឋភាពនៃច្បាប់នេះដែលដាក់ជា បទឧក្រិដ្ឋការងាររកស៊ីផ្លូវភេទ មានឥទ្ធិពលអវិជ្ជមានច្រើន ដែលសម្របសម្រួលឲ្យប៉ូលីស ប្រព្រឹត្ត អំពើឃោរឃៅ អំពើហិង្សា និងការជំរិតទារប្រាក់ ពីអ្នករកស៊ីផ្លូវភេទ ពីជនជួញដូរ និងកុមារ ក្នុងមុខរបររកស៊ីផ្លូវភេទ។ បទបញ្ញត្តិព្រហ្មទណ្ឌស្តីពី “អំពើអូសទាញ” ដោយអ្នក រកស៊ី ផ្លូវភេទ និងនិយមន័យដ៏ទូលំទូលាយស្តីពី “សញ្ចារកម្ម” ដើម្បីគ្របដណ្តប់សកម្មភាពទាំងឡាយទាក់ទងនឹង “ការជួយ ឬការពារអំពើពេស្យាចាររបស់អ្នកដទៃ” រួមទាំង “រារាំងដល់សកម្មភាពបង្ការ ការជួយ ឬការអប់រំឡើងវិញ” របស់អ្នករកស៊ីផ្លូវភេទ គឺ ប្រឈមនឹងការជាប់ជាបទឧក្រិដ្ឋចំពោះការប្រើប្រាស់សិទ្ធិមូលដ្ឋានស្របច្បាប់ ដូចជាសកម្មភាពស្វែងរកការគាំទ្រលើផ្នែកទាំងឡាយ ឬសកម្មភាពអប់រំផ្ទាល់។

ទោសកំហុសបន្ថែមទាំងនេះដែលមានចែងលើសៀវភៅ បានបូកបន្ថែមហេតុផលសម្រាប់ឲ្យមានការបោសសម្អាតកាន់តែខ្លាំងខ្លាឡើងៗក្នុងឆ្នាំ២០០៨និង២០០៩។ ក៏ប៉ុន្តែ ទោះជាមានការផ្តោតចិត្តទុកដាក់លើកិច្ចប្រឹងប្រែងប្រឆាំងនឹងការជួញដូរមនុស្សក៏ដោយ តាមការស៊ើបអង្កេតដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស គឺគ្មានករណីណាមួយនៃការចាប់ខ្លួនស្ថិតក្នុងការប៉ុនប៉ងខ្លះៗរបស់ប៉ូលីស ដើម្បីបែងចែករវាងស្ត្រី និងកុមារក្នុងមុខរបររកស៊ីផ្លូវភេទដោយ ស្ម័គ្រចិត្ត និងអ្នកទាំងឡាយដែលជាជនរងគ្រោះនៃការជួញដូរទេ។ អ្នកប្រកបមុខរបរ រកស៊ីផ្លូវភេទ ងាយទទួលរងនូវការចាប់ឃុំឃាំងពីប៉ូលីស និងបញ្ជូនទៅកាន់មន្ទីរសង្គមកិច្ចរាជធានី ហើយជាយថាហេតុ បញ្ជូនបន្តទៅកាន់អង្គការក្រៅរដ្ឋាភិបាល ឬព្រៃស។

មុនពេលអនុម័តច្បាប់ឆ្នាំ២០០៨ នគរបាលដែលចាប់អ្នកប្រកបរបររកស៊ីផ្លូវភេទ មិនអាច ចោទប្រកាន់ពួកគេពីបទអូសទាញ ពីព្រោះតែវាមិនមែនជាបទល្មើស។ ច្បាប់ប្រឆាំងការជួញដូរពីមុនរបស់ប្រទេសកម្ពុជា គឺច្បាប់ឆ្នាំ១៩៩៦ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស បានដាក់ទោសឧក្រិដ្ឋលើភាគីទីបីដែលពាក់ព័ន្ធ ក្នុងអំពើពេស្យាចារដូចជា មេបន និង “ការបើកទីកន្លែងប្រព្រឹត្តអំពើអនាចារ ឬអំពើ អាសអាភាស។”

តាំងពីច្បាប់ឆ្នាំ២០០៨ចូលជាធរមាន មន្ត្រីប៉ូលីសតែងតែគំរាមកំហែងប្រើប្រាស់នូវបទបញ្ញត្តិស្តីពី “អំពើអូសទាញ” ជាមធ្យោបាយដើម្បីជំរិតយកលុយពីអ្នកប្រកបរបររកស៊ីផ្លូវភេទ ដោយប្រាប់ពួកគេថា ប្រសិនបើពួកគេមិនអោយលុយទេ ពួកគេអាចជាប់គុក ឬ បញ្ជូនដោយបង្ខំទៅកាន់មណ្ឌលរបស់រដ្ឋាភិបាល ពីព្រោះការងាររបស់ពួកគេខុសច្បាប់។ ជាក់ស្តែង មានភស្តុតាងតិចតួចណាស់ដែលថា មានការអនុវត្តច្បាប់តាមអ្វីពិតដូចដែល វាបានចែង ឬ មានការកាត់ទោសអ្នកប្រព្រឹត្តល្មើសនឹងបញ្ញត្តិច្បាប់។ ផ្ទុយទៅវិញ ប៉ូលីសហាក់ដូចជាយកច្បាប់ មកប្រើជាឧបករណ៍សម្រាប់ធ្វើការចោទប្រកាន់ បង្កើតជាហេតុផល ពង្រីកសកម្មភាព ខុសច្បាប់ប្រឆាំងនឹងអ្នកប្រកបរបររកស៊ីផ្លូវភេទ។

ក្នុងឆ្នាំ២០០៨ សកម្មជនខាងការងារជំងឺអេដស៍ បុគ្គលិកធ្វើការខាងសុខភាព និងអ្នកប្រកបរ បររកស៊ីផ្លូវភេទ បានលើកកង្វល់អំពីកំណើននៃការរំលោភពីអាជ្ញាធរ និងការលំបាករបស់ ពួកគេក្នុងការចូលទៅរកអ្នកប្រកបរបររកស៊ីផ្លូវភេទ - ដែលភាគច្រើននៃពួកគេត្រូវបង្ខំឲ្យ ប្រកបរបរនេះដោយលាក់កំបាំង ពីព្រោះតែភ័យខ្លាចការចាប់ខ្លួន។

ដើម្បីដោះស្រាយកង្វល់របស់អ្នកប្រកបរបររកស៊ីផ្លូវភេទ និងរបស់សកម្មជន អំពីការរំលោភ រួមទាំងអ្នកទាំងឡាយដែលរងលទ្ធផលពីច្បាប់ថ្មី ក្នុងខែវិច្ឆិកាឆ្នាំ២០០៨ ក្រុមការងារដឹកនាំ ការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើ អាជីវកម្មផ្លូវភេទលើស្រ្តី និងកុមារ បានចេញ "គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។" យោងតាមគោលការ ណែនាំនេះ សិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរ និងសិទ្ធិរបស់អ្នកប្រកបរបរពេស្យាចារ ត្រូវតែគោរព។ គោលការណ៍នេះចែងថាបុគ្គលពេស្យាចារ ត្រូវចាត់ទុកជា "ជនរងគ្រោះ នៃអំពើសញ្ចោរកម្ម។ អំពើពេស្យាចារមិនមែនជាបទឧក្រិដ្ឋទេ ដូច្នេះអ្នកប្រកបរបរពេស្យាចារ ផ្ទាល់ខ្លួន ពុំត្រូវទទួលការផ្តន្ទាទោសក្រោមច្បាប់ថ្មីនេះឡើយ។"

ខណៈពេលកិច្ចប្រឹងប្រែងទាំងនេះមានលក្ខណៈជាវិជ្ជមាន ក្នុងការផ្តល់ទិសដៅខ្លះៗអំពីរបៀបអនុវត្តច្បាប់នេះ ប៉ែរជាគោលការណ៍នេះមិនលើក បញ្ញត្តិស្តីពីអំពើអូសទាញ មក និយាយទៅវិញ ហើយជាញឹកញយវានាំអោយការអនុវត្តនៅតែជាបញ្ហាដដែល។ សេចក្តី ពន្យល់ ច្បាប់ឆ្នាំ២០០៨ ស្ថិតក្នុងដំណើរការនៃការអភិវឌ្ឍន៍ផងដែរ។

សហរដ្ឋអាមេរិក គឺជាប្រទេសម្ចាស់ជំនួយមួយនៃបណ្តាប្រទេសម្ចាស់ជំនួយទ្វេភាគីដ៏ធំបំផុតនានារបស់ប្រទេសកម្ពុជា និងជាប្រទេសគាំទ្រដ៏ចម្បងលើកិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស។ ស្ថិតក្រោមរដ្ឋបាលរដ្ឋកាលលោកប៊ូស សហរដ្ឋអាមេរិកមានការទទួលខុសត្រូវមួយចំនួនក្នុងគាំទ្រនិងជំរុញឲ្យប្រតិបត្តិច្បាប់ ដែលដាក់ទោសព្រហ្មទណ្ឌលើអ្នកប្រកបរបររក ស៊ីផ្លូវភេទ ដោយមិនពិចារណាឲ្យបានគ្រប់គ្រាន់លើបរិបទនៅមូលដ្ឋាន - បរិបទមួយដែល ប៉ូលីសមានប្រវត្តិប្រព្រឹត្តអំពើរំលោភបំពានជាយូរអង្វែងមកហើយ ប្រឆាំងនឹងអ្នកប្រកបរបររកស៊ីផ្លូវភេទ ជាមួយនឹងនិទណ្ឌភាព។

ប្រទេសកម្ពុជាញាំញី មិនត្រឹមតែដោយការរំលោភដ៏រីករាយដាល ប្រព្រឹត្តដោយមន្រ្តីនានាប៉ុណ្ណោះទេ ប្រទេសនេះថែមទាំងមាននិទណ្ឌភាពសម្រាប់ជនប្រព្រឹត្តល្មើសផងដែរ។ មកទល់សព្វថ្ងៃនេះ មិនមែនមានតែមន្ត្រីប៉ូលីសតែមួយទេដែលត្រូវដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តប្រឆាំងនឹងអ្នកប្រកបរបររកស៊ីផ្លូវភេទ គឺត្រូវមានឆ្មាំសន្តិសុខ មន្ត្រីរដ្ឋាភិបាល ឬនិយោជិតនៅមជ្ឈមណ្ឌលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាផងដែរ។ ការរំលោភអំណាចនិងអំពើនិទណ្ឌភាពដ៏រីករាយដាល បាននាំឲ្យជនរងគ្រោះ រួមទាំងអ្នកប្រកបរបររកស៊ីផ្លូវភេទ ដែលរំលោភដោយប៉ូលីសឬអាជ្ញាធរដទៃទៀត មានការភ័យខ្លាច ឬមានជំនឿតិចតួចក្នុងប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ។ អំពើនិទណ្ឌភាពនេះ មានលក្ខណៈសាមញ្ញទៅហើយនៅក្នុងប្រទេសកម្ពុជា តែបញ្ហានិទណ្ឌភាពនេះនៅតែមិនទាន់ត្រូវបានបំបាត់ចោលបាននៅឡើយ ដើម្បីដាក់ជំនួសមកវិញនូវ នីតិរដ្ឋជាដរាបរាងទៅ។

ដើម្បីប្រឆាំងនឹងសាវតានេះ ប្រទេសកម្ពុជាគួរតែពិនិត្យមើលឡើងវិញនូវច្បាប់និងគោលនយោបាយនានារបស់ខ្លួន ទាក់ទងនឹងការជួញដូរមនុស្សនិងការងារខាងការរកស៊ីផ្លូវភេទ។ ក្រៅពីការការពារជនរងគ្រោះនៃបទឧក្រិដ្ឋ ដូចជាការជួញដូរ និងពេស្យាកម្មដោយបង្ខំ មន្ត្រីរំលោភអំណាច តែងតែកេងយកចំណេញពីច្បាប់និងគោលនយោបាយទាំងនេះ។

# VII. អនុសាសន៍

ចំពោះរដ្ឋាភិបាលកម្ពុជា ៖

- បង្កើត គណៈកម្មាការពិសេសមួយ ដើម្បីដឹកនាំការស៊ើបអង្កេតហ្មត់ចត់ និង ឯករាជ្យទៅលើ អំពើហិង្សានិងការជំរិតទារលុយទាំងអស់ ដែលប្រព្រឹត្តដោយមន្ត្រីប្រតិបត្តិច្បាប់ សន្តិសុខសួនច្បារ និងបុគ្គលិក ឬអ្នកស្ម័គ្រចិត្តក្នុងមណ្ឌលសង្គម កិច្ចរាជធានី។ គណៈកម្មាការ គួរតែមានសមាសភាពពីតំណាងរដ្ឋាភិបាលដែលមានសមត្ថភាព និងមានការគោរព រួមទាំងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង មន្ទីរសង្គមកិច្ច ទីភ្នាក់ងារអង្គការសហ ប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល រួមទាំងក្រុមសិទ្ធិមនុស្ស និងក្រុមអ្នកប្រកប របររកស៊ីផ្លូវភេទ។ គណៈកម្មាការនេះ គួរតែបង្កើតឡើងភ្លាម មានអំណាចហៅសាក្សី និងផលិតរបាយការណ៍សាធារណៈ។ គណៈកម្មាការ គួរមានអំណាច ដាក់ចេញនូវ អនុសាសន៍ សម្រាប់ការស៊ើបអង្កេតខាងព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យប្រាកដថា ជនប្រព្រឹត្តល្មើសនឹងត្រូវបាននាំទៅរកយុត្តិធម៌ចំពោះបទឧក្រិដ្ឋរបស់ពួកគេ។

ចំពោះក្រសួងមហាផ្ទៃ ៖

- គោរពសិទ្ធិរបស់អ្នកប្រកបរបររកស៊ីផ្លូវភេទ ជាពិសេសសិទ្ធិបូរណភាពខាងរាងកាយ សេរីភាព និងសិទ្ធិមានសន្តិសុខ នីតិវិធីត្រឹមត្រូវ និងការមិនរើសអើង ហើយត្រូវការពារពួកគេឲ្យផុតពីរាល់ទម្រង់ទាំងអស់នៃទារុណកម្ម អមនុស្សធម៌ និងការប្រព្រឹត្ត ដោយបន្ទាបបន្ថោក និងដាក់ទណ្ឌកម្ម រួមទាំងរាល់ទម្រង់ទាំងអស់នៃហិង្សាផ្លូវភេទ។
- បញ្ឈប់ការចាប់ខ្លួននិងឃុំឃាំងខ្លួន អ្នកប្រកបរបររកស៊ីផ្លូវភេទ តាមអំពើចិត្ត - រួមទាំង ស្ត្រី កុមារ និងស្រីស្រស់ដែលប្រកបមុខរបររកស៊ីផ្លូវភេទ - អ្នករងគ្រោះនៃអំពើជួញដូរ និងអ្នកដទៃទៀត រួមទាំងអ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសំបែង អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកជំងឺវិកលចរិត។
- ស៊ើបអង្កេត និងនាំមកកាត់ទោស ជនប្រព្រឹត្តល្មើសរំលោភសិទ្ធិមនុស្សប្រឆាំងនឹង អ្នកប្រកបរបររកស៊ីផ្លូវភេទ រួមមានទាំងប៉ូលីស និងមន្ត្រីរដ្ឋាភិបាល។
- ទទួលស្គាល់និងថ្កោលទោសជាសាធារណៈ ចំពោះការរំលោភរបស់ប៉ូលីសនិងបុគ្គលិកមណ្ឌលសង្គមកិច្ចប្រឆាំងនឹង អ្នកប្រកបរបររកស៊ីផ្លូវភេទ ។
- ផ្សព្វផ្សាយយ៉ាងទូលំទូលាយភ្លាមៗ និងណែនាំមន្ត្រីប្រតិបត្តិច្បាប់ទាំអស់ ជាពិសេស ប៉ូលីសមូលដ្ឋាននៅកម្រិតឃុំ/សង្កាត់ ខ័ណ្ឌ/ស្រុក រាជធានី/ខែត្រ និងមន្ត្រីមូលដ្ឋាននៅកម្រិតឃុំ/សង្កាត់ ខ័ណ្ឌ/ស្រុក រាជធានី/ខែត្រ ឲ្យប្រកាន់ខ្ជាប់នូវគោលការណ៍ ណែនាំឆ្នាំ២០០៨ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ។
- ដោយប្រឹក្សាជាមួយក្រុមសហគមន៍ ក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ ក្រុមសិទ្ធិមនុស្ស ក្រុមប្រឆាំងអំពើជួញដូរមនុស្ស ក្រុមធ្វើការងារខាងវិស័យសុខភាព និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ត្រូវដឹកនាំការពិនិត្យមើលឡើងវិញនូវច្បាប់ ឆ្នាំ២០០៨ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងផលប៉ះពាល់របស់ច្បាប់នេះលើ អ្នកប្រកបរបររកស៊ីផ្លូវភេទ មុនពេលអនុវត្តបទបញ្ញត្តិច្បាប់ ទាក់ទងនឹងមុខរបររកស៊ីផ្លូវភេទទាំងនោះ។
- ក្រើនរំឭកដល់បុគ្គលិកមិនមែនជាប៉ូលីស ដូចជា សន្តិសុខសួនច្បារ និងសន្តិសុខខណ្ឌ ដែលពួកគេមិនមានអំណាចចាប់ខ្លួន និងសូមផ្តល់ដំបូន្មានដល់ពួកគេថា ប្រសិនពួកគេដកហូតសេរីភាពអ្នកដទៃដោយខុសច្បាប់ នោះពួកគេត្រូវប្រឈមនឹង ការនាំខ្លួនទៅកាត់ទោសក្រោមច្បាប់។
- បង្កើនចំនួនមន្ត្រីប្រតិបត្តិច្បាប់ភេទស្ត្រី ដែលមានការហ្វឹកហ្វឺនក្នុងកិច្ចការដោះ ស្រាយស្ថានការណ៍ទាក់ទិននឹងហិង្សាផ្អែកលើយ៉េនឌ័ និងចូរធានាថា មន្ត្រីជាស្ត្រីត្រូវបានប្រគល់កិច្ចការកាន់កាប់ករណីទាក់ទងនឹង ស្ត្រី និងស្រស្រស់ ប្រកបរបរ រកស៊ីផ្លូវភេទ។ សូមបង្កើនចំនួនមន្ត្រីប៉ូលីសជាស្ត្រីជាអប្សរមា នៅ ទួលគោក

ចំការមន និងដូនពេញ ជាកន្លែងដែលមានរបាយការណ៍ពីការរំលោភយ៉ាងច្រើន។ សូមហ្វឹកហ្វឺនមន្ត្រីទាំងនេះពីការសម្ភាសន៍ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដើម្បីកំណត់ចុងក្រោយថាតើពួកគេ ជាជនរងគ្រោះនៃអំពើជួញដូរ ឬនៃអំពើរំលោភលើ រូបរាងកាយ និងត្រូវធ្វើស្របទៅតាមបទដ្ឋានសិទ្ធិមនុស្ស ក្នុងការដោះស្រាយបញ្ហាជាមួយនីតិជន និងអនីតិជន ក្នុងមុខរបររកស៊ីផ្លូវភេទ ។ សូមហ្វឹកហ្វឺនពួកគេ ផងដែរ អំពីការផ្តល់ សេចក្តីពន្យល់ ខាងផ្លូវភេទ និងអត្តសញ្ញាណ និងការសម្តែងផ្នែកយ៉េនឌឺ រួមទាំងអត្តសញ្ញាណស្រីស្រស់។

- សូមណែនាំមន្ត្រីប្រតិបត្តិច្បាប់ថា ពួកគេអាចឃុំខ្លួនបានតែ អ្នកប្រកបរបររកស៊ី ផ្លូវភេទជានីតិជន ប្រសិនបើពួកគេបានប្រព្រឹត្តបទល្មើសជាក់ស្តែងក្រោមច្បាប់ និងពួកគេមានបំណងចោទប្រកាន់ភ្លាមៗនិងនាំពួកគេទៅផ្តន្ទាទោសចំពោះ បទល្មើស នោះ។ ប្រសិនបើ អ្នកប្រកបរបររកស៊ីផ្លូវភេទជានីតិជន ត្រូវបានផ្ទេរទៅអង្គការមិនមែនរដ្ឋាភិបាល ដូច្នេះត្រូវធ្វើឡើងដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តយ៉ាងពិតៗ និងប្រាប់ទៅអង្គការមិនមែនរដ្ឋាភិបាលនោះឲ្យផ្តល់សេវា និងកន្លែងស្នាក់នៅសមស្រប។
- ណែនាំដល់មន្ត្រីប្រតិបត្តិច្បាប់ ឲ្យបញ្ជូនកុមារ និងជនរងគ្រោះនៃអំពើជួញដូរទៅកាន់អង្គការមិនមែនរដ្ឋាភិបាលដែលមានសេវាសមស្រប ក្នុងកិច្ចការពារពួកគេស្របតាមបទដ្ឋានអន្តរជាតិ។
- ណែនាំដល់មន្ត្រីប្រតិបត្តិច្បាប់ថា កុមារក្នុងមុខរបររកស៊ីផ្លូវភេទ មិនត្រូវទទួលរង នូវការប្រព្រឹត្តមកលើខ្លួនគេដូចជាអ្នកទោសទេ និងមិនត្រូវឃុំឃាំងពួកគេដោយគ្រាន់តែពួកគេមានមុខរបររកស៊ីផ្លូវភេទ នោះដែរ។
- ក្នុងករណីដែលនីតិជន ឬអនីតិជន មានការចង្អុលបង្ហាញថាខ្លួនគេនោះ អាចទទួលរងនូវការជួញដូរ សូមបញ្ជូនពួកគេជាបន្ទាន់ទៅកាន់អង្គការមិនមែនរដ្ឋាភិបាលមួយដែលផ្តល់ជំនួយដល់ជនរងគ្រោះនៃអំពើជួញដូរ និងដែលសេវារបស់ពួកគេមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិ។
- រៀបចំនិងពង្រឹងគោលនយោបាយ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលជួយ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដែលត្រូវការសេវាទាំងអស់នោះ រួមទាំងការដឹកជញ្ជូន និងទីជម្រក ដោយផ្តល់តាមមូលដ្ឋានស្ម័គ្រចិត្ត និងយល់ព្រមយក។ ចាត់វិធានការ ប្រឆាំងនឹងអង្គការណាដែលអនុវត្តការបង្ខិតបង្ខំឲ្យបុគ្គលស្ថិតនៅតែក្នុងមណ្ឌលប្រឆាំងនឹងឆន្ទះរបស់ពួកគេ។

ចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖

- សូមបិទមជ្ឈមណ្ឌលព្រៃស្ពឺ និងកោះគរជាស្ថាពរ រួមទាំងមណ្ឌលដទៃទៀតរបស់ក្រសួងសង្គមកិច្ច ដែលបានឃុំឃាំងប្រជាពលរដ្ឋរំលោភលើច្បាប់ជាតិនិងអន្តរជាតិ។
- សូមព្យួរការងារបុគ្គលិក ដែលជាប់ចោទពីបទរំលោភដែលគួរជឿបាន។
- ទទួលស្គាល់និងថ្កោលទោសជាសាធារណៈចំពោះអំពើរំលោភដោយប៉ូលីស និងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ចទៅលើ អ្នកប្រកបរបររកស៊ីផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតលើពួកគេ។
- ប្រឹក្សាជាមួយក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ ដើម្បីរួមគ្នាបង្កើតកម្មវិធី និងសេវា ដែលអាចផ្តល់អំណាចដល់អ្នកប្រកបរបររកស៊ីផ្លូវភេទ និងឆ្លុះបញ្ចាំងឲ្យឃើញ អំពីសេចក្តីត្រូវការពិតៗរបស់ពួកគេ។ សេចក្តីត្រូវការមានរួមទាំងជំនួយផ្នែកច្បាប់ ការថែទាំសុខភាព ការថែទាំកុមារ ឬការហ្វឹកហ្វឺនវិជ្ជាជីវៈ ប្រសិនបើ អ្នកប្រកបរបររកស៊ីផ្លូវភេទ កត់សំគាល់ឃើញថាវាពាក់ព័ន្ធសម្រាប់ពួកគេ។

ចំពោះសាលារាជធានីភ្នំពេញ ៖

- បញ្ឈប់ការចាប់ខ្លួននិងឃុំឃាំងខ្លួនអ្នកប្រកបរបររកស៊ីផ្លូវភេទ តាមអំពើចិត្ត - រួមទាំង ស្រ្តី បុរស កុមារ និងស្រីស្រស់ប្រកបរបររកស៊ីផ្លូវភេទ - ជនរងគ្រោះនៃអំពើជួញដូរ និងអ្នកដទៃទៀត រួមមានអ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសំបែង អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកមានជំងឺវិកលចរិត។
- ទទួលស្គាល់និងថ្កោលទោសជាសាធារណៈចំពោះអំពើរំលោភដោយប៉ូលីស និង បុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ចទៅលើអ្នកប្រកបរបររកស៊ីផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតពួកគេ។
- ផ្សព្វផ្សាយ និងណែនាំឲ្យបានទូលំទូលាយ ដល់មន្រ្តីមូលដ្ឋានទាំងអស់នៅកម្រិតឃុំ/សង្កាត់ ស្រុក/ខ័ណ្ឌ រាជធានី/ខេត្រ ដើម្បីពង្រឹងគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់បង្រ្កាបអំពើការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ចំពោះរដ្ឋសភាជាតិនៃប្រទេសកម្ពុជា ៖

- ទទួលស្គាល់និងថ្កោលទោសជាសាធារណចំពោះអំពើរំលោភដោយប៉ូលីស និងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ចទៅលើ អ្នកប្រកបរបររកស៊ីផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតលើពួកគេ។
- បង្កើតស្ថាប័នឯករាជ្យមួយ ដើម្បីទទួលពាក្យបណ្តឹងស្តីពីទារុណកម្ម ការប្រព្រឹត្ត ដែលឃោរឃៅ បន្ទាបបន្ថោក និងអមនុស្សធម៌ និងការរំលោភផ្សេងៗទៀតដែលប្រព្រឹត្តដោយមន្រ្តីប្រតិបត្តិច្បាប់ និងបុគ្គលិកនៅមជ្ឈមណ្ឌលសង្គមកិច្ច។
- រហូតទាល់តែមានការដោះស្រាយបញ្ហាដ៏រាលដាល នៃការរំលោភលើ អ្នកប្រកបរបរ រកស៊ីផ្លូវភេទ  សូមព្យួរមាត្រា២៤ ស្តីពី “អំពើអូសទាញ” ក្នុងច្បាប់ស្តីពីការបង្រ្កាប អំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បទបញ្ញត្តិនេះ ផ្តល់ឲ្យប៉ូលីសនូវ អំណាចបន្ថែមដើម្បីជំរិតទាលុយ និងប្រព្រឹត្តអំពើហិង្សាប្រឆាំងនឹង អ្នកប្រកបរបរ រកស៊ីផ្លូវភេទ និងសម្រួលអោយមានការរំលោភ។
- សូមលប់ចោលមាត្រាដែលមិនច្បាស់លាស់ គឺមាត្រា២៥(៣)នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបញ្ញត្តិនេះចាត់ជា “ការរារាំងដល់សកម្មភាពបង្ការ ការជួយ ឬការអប់រំឡើងវិញ” របស់អ្នកប្រកបរបររកស៊ីផ្លូវភេទ ដែលមានន័យស្មើនឹងសញ្ចារកម្ម។

ចំពោះទីភ្នាក់ងារសហប្រជាជាតិ និងរដ្ឋាភិបាលម្ចាស់ជំនួយពាក់ព័ន្ធ រួមទាំងសហរដ្ឋអាមេរិក សហគមន៏អឺរ៉ុប ជប៉ុន និងអូស្រ្តាលី ៖

- ស្នើសុំឲ្យបិទមជ្ឈមណ្ឌលព្រៃស្ពឺនិងកោះគរជាស្ថាពរ រួមទាំងមណ្ឌលដទៃទៀតរបស់ក្រសួងសង្គមកិច្ច ដែលបានឃុំឃាំងប្រជាពលរដ្ឋរំលោភលើច្បាប់ជាតិនិងអន្តរជាតិ។
- ស្នើសុំឲ្យរដ្ឋាភិបាលនៃប្រទេសកម្ពុជាធ្វើការស៊ើបអង្កេតជាបន្ទាន់និងដោយឯករាជ្យលើរាល់ការចោទប្រកាន់ទាំងអស់អំពីអំពើរំលោភប្រឆាំងនឹង អ្នកប្រកបរបររកស៊ីផ្លូវភេទ ដោយប៉ូលីសនិងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ច។
- ពិនិត្យមើលឡើងវិញនូវរាល់មូលនិធិ កម្មវិធី និងសកម្មភាពទាំងអស់ ដែលគេដាក់ជួយដល់ក្រសួងសង្គមកិច្ចរបស់ប្រទេសកម្ពុជា ដើម្បីធ្វើឲ្យប្រាកដថាគ្មានមូលនិធិកំពុងគាំទ្រដល់គោលនយោបាយ ឬកម្មវិធីដែលរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចជាការហាមឃាត់ចំពោះការចាប់ខ្លួននិងឃុំខ្លួនតាមអំពើចិត្ត អំពើទារុណកម្ម និងការប្រព្រឹត្តបែបបន្ទាបបន្ថោកនិងអមនុស្សធម៌ទៅលើ អ្នកប្រកបរបររកស៊ីផ្លូវភេទ ។

- ពិនិត្យមើលឡើងវិញនូវរាល់មូលនិធិ កម្មវិធី និងសកម្មភាពទាំងអស់ ដែលគ្រោងឡើងដើម្បីជួយដល់ប៉ូលីសកម្ពុជា និងក្រសួងសង្គមកិច្ច រហូតទាល់តែមានការស៊ើបអង្កេតមួយដែលឯករាជ្យពេញលេញ ចំពោះការចោទប្រកាន់ពីអំពើរំលោភ និងការនាំខ្លួនជនទាំងឡាយ ដែលរឃើញថាបានទទួលខុសត្រូវចំពោះអំពើរំលោភទាំងនោះនិងសូមឲ្យបិទជាស្ថាពរនូវមជ្ឈមណ្ឌលព្រៃស្ពឺនិងកោះគរ ។
- ជំរុញយ៉ាងសកម្មឲ្យរដ្ឋាភិបាលកម្ពុជាអនុម័ត និងដាក់ឲ្យអនុវត្តនូវសេវាកម្ម និង កម្មវិធី សម្រាប់ អ្នកប្រកបរបររកស៊ីផ្លូវភេទ ដោយឈរលើមូលដ្ឋានស្ម័គ្រចិត្ត ដោយមានការចូលរួមពីក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ ។
- គាំទ្រដល់អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល និងក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ ដែលកំពុងជួយដល់អ្នកប្រកបរបររកស៊ីផ្លូវភេទ តាមមូលដ្ឋានស្ម័គ្រចិត្ត និងតាមបែប ចូលរួម។
- គាំទ្រត្រឹមតែក្រុមសង្គមស៊ីវិលណា ដែលគ្រប់គ្រងទីមណ្ឌលផ្តល់សេវា ស្របទៅតាមបទដ្ឋានអន្តរជាតិ។
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស គួរដឹកនាំ ការស៊ើបអង្កេតដោយឯករាជ្យនិងឥតលំអៀង ចំពោះអំពើហិង្សានិងអំពើជំរិតដោយកងកម្លាំងសន្តិសុខ និង សន្តិសុខសួនច្បារ និងប្រកាសជាសាធារណៈអំពី ការរក ឃើញអំពើរំលោភរបស់កងកម្លាំងទាំងនេះ។

ចំពោះរដ្ឋាភិបាលសហរដ្ឋអាមេរិក ៖

- បន្ថែមទៅនឹងការគាំទ្រដល់អនុសាសន៍ខាងលើ សូមទទួលស្គាល់ស្ថានភាពងាយរង គ្រោះរបស់ អ្នកប្រកបរបររកស៊ីផ្លូវភេទ និងធានាថា ពួកគេនឹងមិនទទួលរងការដាក់ ទណ្ឌកម្មតទៅទៀត ដោយសារលទ្ធផលគោលនយោបាយសហរដ្ឋអាមេរិកឡើយ។
- ទទួលស្គាល់ផលប៉ះពាល់នៃរបាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំនៅបណ្តាប្រទេសដទៃទៀត និងទទួលស្គាល់និងដោះស្រាយគ្រោះថ្នាក់ ដែលបានកើតចេញ មកពី យុទ្ធនាការប្រឆាំងការជួញដូរមនុស្សដែលខុសឆ្គងកន្លងមក ដោយត្រូវធ្វើការ សរសេរចងក្រងនូវផលប៉ះពាល់លើជនរងគ្រោះនៃការជួញដូរ ផលប៉ះពាល់លើ អ្នកប្រកបរបររកស៊ីផ្លូវភេទ និងក្រុមដែលគេចាត់ជាកាកសង្គម ដទៃទៀត ដូចជាអ្នក ចំណាកស្រុកដែលគេមិនចុះបញ្ជីឲ្យជាដើម។

ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលជួយជនរងគ្រោះនៃអំពើជួញដូរ និង អ្នកប្រកបរបររកស៊ីផ្លូវភេទ ៖

- សូមអនុវត្តឲ្យបានពេញលេញទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ លើការប្រព្រឹត្តចំពោះអ្នករងគ្រោះនៃអំពើជួញដូរ និងអាជីវកម្មផ្លូវភេទ។ ជាពិសេស សូមធានាថារាល់គោលនយោបាយទាំងអស់ស្តីពីការទទួលឲ្យចូល និងឲ្យចេញពីមណ្ឌលខ្លួន គឺត្រូវផ្អែកលើការគោរពយ៉ាងខ្ជាប់ខ្ជួនចំពោះសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន និងសេរីភាពក្នុងការធ្វើដំណើរ ស្វ័យភាពនិងភាពជាឯកជន ការមិនរើសអើង និងហាម ឃាត់លើការប្រព្រឹត្តបែបបន្ទាបបន្ថោក និងអមនុស្សធម៌។ សូមធ្វើការប្តេជ្ញាចិត្តចំពោះ គោលនយោបាយនេះជាលាយល័ក្ខអក្សរ។